# ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា

## ជំពូក ៣
## ការត្រួតពិនិត្យប្រតិបត្តិករដោះមីន

---

អគ្គលេខាធិការដ្ឋាន
អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
អគារប្ញីផ្លូវលេខ ២៧៣ កែង ៥១៦ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ
ទូរស័ព្ទលេខ: ០២៣-៨៨៥-៩៤១ | ០២៣-៨៨១-៤៩២
គេហទំព័រ: www.cmaa.gov.kh

# មាតិកា


មាតិកា ....................................................................................................... ២
សេចក្តីផ្តើម ................................................................................................... ៤
ការត្រួតពិនិត្យប្រតិបត្តិករដោះមីន ...................................................................... ៥
១. ទ្រង់ទ្រាយ................................................................................................. ៥
២. គោលការណ៍ទូទៅ......................................................................................... ៥
៣. តម្រូវការទូទៅ ........................................................................................... ៥
៣.១. ផែនការ និង ការរៀបចំ................................................................................ ៥
៣.២. ការត្រួតពិនិត្យ ....................................................................................... ៦
៣.២.១. ទូទៅ ................................................................................................ ៦
៣.២.២. ការអនុវត្តជាក់ស្តែង និង ការរៀបចំឯកសារ ...................................................... ៧
៣.២.៣. សុវត្ថិភាពនៅការដ្ឋាន ........................................................................... ៧
៣.២.៤. ការគាំទ្រផ្នែកពេទ្យ .............................................................................. ៧
៣.២.៥. ការរក្សាទុក ការដឹកជញ្ជូន និង ការប្រើប្រាស់វំសេវផ្ទុះ ...................................... ៨
៣.២.៦. ការស៊ើបអង្កេតឧប្បត្តិហេតុ និង គ្រោះថ្នាក់ .................................................. ៨
៣.២.៧. សម្ភារៈ ............................................................................................ ៨
៣.២.៨. សកម្មភាពបោសសម្អាតមីន...................................................................... ៨
៣.៣. ការធ្វើរបាយការណ៍..................................................................................... ៩
៣.៤. ការកែតម្រូវ ............................................................................................ ៩
៤. អង្គភាពត្រួតពិនិត្យ កាតព្វកិច្ចទូទៅ .................................................................. ៩
៤.១. ទូទៅ..................................................................................................... ៩
៤.២. អង្គការចាត់តាំង ...................................................................................... ១០
៤.៣. ប្រព័ន្ធគ្រប់គ្រង ...................................................................................... ១០
៤.៤. ឯករាជភាព អព្យាក្រិតភាព និង បូរណភាព ......................................................... ១១
៥. ការទទួលខុសត្រូវ........................................................................................ ១១
៥.១. ការទទួលខុសត្រូវរបស់អាជ្ញាធរមីន ................................................................ ១១
៥.២. ការទទួលខុសត្រូវរបស់អង្គភាពត្រួតពិនិត្យ........................................................ ១២
៥.៣. ការទទួលខុសត្រូវរបស់ប្រតិបត្តិករដោះមីន ........................................................ ១២
៥.៤. ការទទួលខុសត្រូវរបស់ប្រទេសផ្តល់ជំនួយ .......................................................... ១៣


***

# សេចក្ដីផ្ដើម

ការគ្រប់គ្រងគុណភាពនៃដំណើរការដោះមីន គឺជាសមិទ្ធផលដែលសម្រេចបាន តាមរយៈការទទួល ស្គាល់ជាផ្លូវការ និងការត្រួតពិនិត្យ ប្រតិបត្តិករដោះមីន មុន និងក្នុងអំឡុងពេលដំណើរការបោសសម្អាត និងការធ្វើអធិការកិច្ចដីដែលបានបោសសម្អាតមីនរួច មុននឹងផ្ទេរ ឬ ប្រគល់ជាផ្លូវការ ។

អាជ្ញាធរមីន នឹងអនុវត្តការត្រួតពិនិត្យផ្ទៃក្រៅ ដើម្បីបញ្ជាក់ថា ប្រតិបត្តិករដោះមីន អនុវត្តដំណើរការ គ្រប់គ្រងដែលមានការឯកភាព និងបទដ្ឋានប្រតិបត្តិការ ក្នុងលក្ខណៈដែលមានសុវត្ថិភាព ប្រសិទ្ធភាព និងសុក្រឹតភាពក្នុងការបោសសម្អាតមីន។ ការត្រួតពិនិត្យ គឺជាសកម្មភាពដ៏ចម្បងមួយ ដែលទទួលរ៉ាប់រង អនុវត្តដោយអាជ្ញាធរមីន។ ការងារនេះរួមមាន ការសង្កេតមើលការធ្វើកំណត់ហេតុ និងការធ្វើរបាយការណ៍។

គោលបំណងរបស់ស្តង់ដានេះ គឺដើម្បីផ្តល់ឲ្យនូវគម្រោងសម្រាប់ការអនុវត្តប្រព័ន្ធត្រួតពិនិត្យ ដែលជាផ្នែកមួយ នៃដំណើរការដោះមីននៅកម្ពុជា ព្រមទាំងការបង្កើនលទ្ធភាពរួមមួយ និងមានស្ថេរភាពទៅនឹងការត្រួតពិនិត្យផ្ទៃក្រៅនៃអង្គការដោះមីន ។

# ការត្រួតពិនិត្យប្រតិបត្តិករដោះមីន

## ១. ទំហំវិសាលភាព

ស្តង់ដានេះ ផ្តល់នូវគោលការណ៍ណែនាំសម្រាប់អនុវត្តប្រព័ន្ធត្រួតពិនិត្យលើប្រតិបត្តិករដោះមីននៅកម្ពុជា ។ ថ្វីត្បិតតែស្តង់ដានេះ ផ្តោតទៅលើការបោសសម្អាតមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ តែគោលការណ៍ត្រួតពិនិត្យ អាចអនុវត្ត ចំពោះសមាសភាពសកម្មភាពកំចាត់មីនផ្សេងទៀត រាប់បញ្ចូលទាំងគម្រោងស្រាវជ្រាវផលប៉ះពាល់ និងគម្រោងអប់រំអំពីគ្រោះថ្នាក់ដោយសារមីន ។

## ២. គោលការណ៍ទូទៅ

ការត្រួតពិនិត្យ គឺជាផ្នែកមួយដ៏សំខាន់ នៃការគ្រប់គ្រងគុណភាពលើដំណើរការបោសសម្អាតមីន ព្រមជាមួយនឹងការទទួលស្គាល់ជាផ្លូវការ និងការធ្វើអធិការកិច្ចក្រោយបោសសម្អាតមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ គោលការណ៍នេះ បានផ្តល់ឲ្យអាជ្ញាធរមីន នូវទំនុកចិត្តលើអង្គការដោះមីន ថាបានបោសសម្អាតមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ដោយអនុលោមទៅតាមកិច្ចសន្យា ហើយដីនោះមានសុវត្ថិភាពសម្រាប់ប្រើប្រាស់។

ដើម្បីសម្រេចគោលបំណងនេះ ការត្រួតពិនិត្យ ត្រូវមើលលើសមត្ថភាពដោះមីនរបស់ប្រតិបត្តិករដោះមីន (ធនធានមនុស្ស សម្ភារៈ និងនីតិវិធី) និងការសង្កេតមើលពីរបៀបអនុវត្តសមត្ថភាពនេះ ។ ការត្រួតពិនិត្យដោយផ្នែខាងក្រៅ គឺដើម្បីបំពេញប្រព័ន្ធគ្រប់គ្រងគុណភាពផ្ទៃក្នុងរបស់ប្រតិបត្តិករដោះមីន ដើម្បីបញ្ជាក់ថាបទដ្ឋានធានាគុណភាពរបស់ប្រតិបត្តិករដោះមីន និងការធ្វើអធិការកិច្ចលើការត្រួតពិនិត្យគុណភាព ផ្ទៃក្នុង មានលក្ខណៈសមរម្យ និងត្រូវបានអនុវត្ត ប៉ុន្តែវាមិនអាចជំនួសឲ្យការទទួលខុសត្រូវរបស់ប្រតិបត្តិករដោះមីន ក្នុងការធានាការអនុវត្តនូវបទដ្ឋានប្រតិបត្តិការ ឲ្យមានសុវត្ថិភាព ប្រសិទ្ធភាព និង សុក្រឹតភាពឡើយ ។

ការត្រួតពិនិត្យ នឹងត្រូវបានគេប្រើផងដែរ ជាពិសេសនៅពេលចាប់ផ្តើមគម្រោងកម្មវិធីបោសសម្អាតមីន ដូចជាការត្រួតពិនិត្យមើលនៅការដ្ឋាន ដែលជាផ្នែកនៃដំណើរការផ្តល់ប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណ ។ គោលការណ៍ណែនាំពីការផ្តល់ប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណ មានចែងនៅក្នុងស្តង់ដាជំពូក ២ ។

## ៣. តម្រូវការទូទៅ

### ៣.១. ការធ្វើផែនការ និងការរៀបចំ

ការចុះត្រួតពិនិត្យមើលការដ្ឋានដែលធ្វើឡើងដោយអាជ្ញាធរមីន ត្រូវត្រៀមរៀបចំឲ្យបានល្អ ដោយបញ្ចូលនូវព័ត៌មានលំអិតពីសកម្មភាពដែលកើតឡើងជាញឹកញាប់ ហើយទម្រង់បែបបទនៃការចុះត្រួតពិនិត្យនេះ ត្រូវបង្កើតឡើងឲ្យបានច្បាស់លាស់ជាមួយប្រតិបត្តិករដោះមីន ដែលត្រូវត្រួតពិនិត្យ ។ មុននឹងធ្វើការត្រួតពិនិត្យ នៅការដ្ឋានណាមួយ អាជ្ញាធរមីនត្រូវអានឯកសារដែលពាក់ព័ន្ធទាំងអស់ រាប់បញ្ចូលទាំងកិច្ចព្រមព្រៀងបោសសម្អាតមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ កិច្ចព្រមព្រៀងផ្តល់ប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណ ឯកសារអនុវត្តការគ្រប់គ្រង និងបទដ្ឋានប្រតិបត្តិការ របាយការណ៍ពីការត្រួតពិនិត្យមុនៗ លទ្ធផលអធិការកិច្ចក្រោយការបោសសម្អាតមីនរួច របាយការណ៍ឧប្បត្តិហេតុ ការស៊ើបអង្កេត និងព័ត៌មានទាំងឡាយដែលនឹងអាចជួយឲ្យអាជ្ញាធរមីនបង្កើតផែនការ និងកម្មវិធីសម្រាប់ត្រួតពិនិត្យការដ្ឋានបាន ។

មុននឹងចុះត្រួតពិនិត្យ អាជ្ញាធរមីនត្រូវជូនដំណឹងដល់ប្រតិបត្តិករដោះមីនពីគោលបំណង និងកម្មវិធី ព្រមទាំងការរៀបចំដែលតម្រូវឲ្យមាន (ដូចជាការធានាឲ្យមានឯកសារដាក់លាក់ ឬ បុគ្គលិកសំខាន់ៗ)។ កាលបរិច្ឆេទ និង ពេលវេលាពិតប្រាកដ នៃការចុះពិនិត្យការដ្ឋាន អាចផ្តល់ឲ្យជាមុន ឬ អាចមិនប្រកាសឲ្យដឹងមុនក៏បាន ។

### ៣.២. ការត្រួតពិនិត្យ

### ៣.២.១. គោលការណ៍ទូទៅ

អាជ្ញាធរមីន ត្រូវចុះត្រួតពិនិត្យប្រតិបត្តិករដោះមីន និងអង្គភាពចំណុះ ដើម្បីបញ្ជាក់ថា ប្រព័ន្ធគ្រប់គ្រង និងបទដ្ឋានប្រតិបត្តិការ ស្របទៅតាមខ្លឹមសារនៃប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណ ។ ការត្រួតពិនិត្យទាំងនេះ ត្រូវធ្វើឡើងដោយជ្រើសរើស និងមិនជ្រៀតជ្រែកជាមួយការអនុវត្តគម្រោងផែនការសកម្មភាពបោសសម្អាតមីន ។

**ការត្រួតពិនិត្យនៅការដ្ឋានរួមមាន៖**

ក)-ពិនិត្យមើលការគ្រប់គ្រង ការិយាល័យភស្តុភារ និងរដ្ឋបាល ឬ មធ្យោបាយនានា រួមមាន កន្លែងទុកដាក់រំសេវផ្ទុះ មធ្យោបាយព្យាបាល កន្លែងថែទាំសម្ភារៈ ។

ខ)-ចុះពិនិត្យមើលទីតាំងរបស់អង្គភាពចំណុះ រួមទាំងការដ្ឋាន និងកន្លែងគាំទ្រដល់កិច្ចប្រតិបត្តិការ ។

គ)-សង្កេតមើលសកម្មភាពបោសសម្អាតមីន រួមទាំងការធានាគុណភាពផ្ទៃក្នុង និងនីតិវិធី ត្រួតពិនិត្យគុណភាព ការបំផ្លាញគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ពិសេស បើគ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះទាំងនោះ ត្រូវបានបំផ្លាញចោលនៅក្រៅការដ្ឋាន។

ឃ)-ធ្វើសវនកម្មលើប្រព័ន្ធគ្រប់គ្រងគុណភាពរបស់ប្រតិបត្តិករដោះមីន។

ង)-បើអាច ត្រូវធ្វើការសង្កេតមើលការសាកល្បងនៅតាមការដ្ឋាន និងការវាយតម្លៃលើសម្ភារៈ។

### ៣.២.២. ការអនុវត្តការគ្រប់គ្រង និង ការរៀបចំឯកសារ

ការត្រួតពិនិត្យ ត្រូវដាក់បញ្ចូលទាំងការធ្វើអធិការកិច្ច លើការរៀបចំឯកសារគ្រប់គ្រងការដោះមីន ឧទាហរណ៍ៈ គុណសម្បត្តិ កំណត់ហេតុហ្វឹកហ្វឺន ការធានារ៉ាប់រង ការពិនិត្យសុខភាពវិជ្ជាជីវៈជាទូទៅ និងកំណត់ហេតុ។ ឯកសារការងាររដ្ឋបាលប្រចាំថ្ងៃ ព័ត៌មានផ្ទាល់ខ្លួនរបស់និយោជិក និងព័ត៌មាន ដែលជាអាថ៌កំបាំង មិនត្រូវធ្វើអធិការកិច្ចឡើយ។ គំរូនៃឯកសារ និងកំណត់ហេតុ ដែលបានរៀបរាប់ខាងលើ ត្រូវបានជ្រើសរើសដោយត្រួសៗ និងជាតំណាងឲ្យឯកសារទាំងអស់ដែលពាក់ព័ន្ធ ។

### ៣.២.៣. សុវត្ថិភាពនៅការដ្ឋាន

លក្ខខ័ណ្ឌចាំបាច់នៃសុវត្ថិភាពការងារ រាប់បញ្ចូលទាំងការរៀបចំគម្រោងការ នៃការដ្ឋានបោសសម្អាតមីន ដោយដាក់សញ្ញាសម្គាល់តំបន់គ្រោះថ្នាក់ ការត្រួតពិនិត្យចលនារបស់អ្នកដោះមីន ភ្ញៀវ និងប្រជាពលរដ្ឋមូលដ្ឋាន ពង្រឹងចម្ងាយសុវត្ថិភាព និងផ្តល់ការព្យាបាល ដែលមានប្រសិទ្ធភាព និងបទដ្ឋានដឹកជញ្ជូនជនរងគ្រោះ ។ នីតិវិធីបទដ្ឋាននៅការដ្ឋាន ត្រូវស្របទៅតាមស្តង់ដាជាតិ និងអនុវត្តស្របទៅតាមបទដ្ឋានប្រតិបត្តិការរបស់អង្គការប្រតិបត្តិករផ្ទាល់ ។ អាជ្ញាធរមីន នឹងវាយតម្លៃលើគម្រោងការលើការដ្ឋាន ការងារ និងបទដ្ឋានសុវត្ថិភាព ដើម្បីបញ្ជាក់ពីកម្រិតប្រសិទ្ធភាពនៃការអនុវត្តបទដ្ឋានទាំងនោះ ។ ស្តង់ដាស្តីពីការណែនាំសុវត្ថិភាពនៅការដ្ឋានបោសសម្អាតមីន និងតម្រូវការកំរិតអប្បបរមានៃសម្ភារៈ សម្រាប់ពាក់ការពារខ្លួននៅការដ្ឋាន នឹងត្រូវបានចងក្រងនៅពេលខាងមុខ។

### ៣.២.៤. ការគាំទ្រផ្នែកពេទ្យ

ការអភិវឌ្ឍសមត្ថភាព គាំទ្រផ្នែកពេទ្យឲ្យបានសមស្រប តម្រូវឲ្យមានផែនការល្អ បុគ្គលិកមានឯកទេសត្រឹមត្រូវ និងមានសេវាកម្មផ្នែកពេទ្យគ្រប់គ្រាន់ ដែលអាចផ្តល់ឲ្យការព្យាបាលបន្ទាន់មានប្រសិទ្ធភាព ។ អាជ្ញាធរមីន នឹងវាយតម្លៃលើសេវាគាំទ្រផ្នែកពេទ្យនៅការដ្ឋាន រួមទាំងសមត្ថភាពរបស់បុគ្គលិកពេទ្យ បរិក្ខារពេទ្យ កន្លែងទុកដាក់ការផ្គត់ផ្គង់ និងថ្នាំពេទ្យដែលផ្តល់ឲ្យបុគ្គលិកពេទ្យ រថយន្តសង្គ្រោះបន្ទាន់ ឯកសារបទដ្ឋានផ្សេងៗសម្រាប់ព្យាបាល និងការសង្គ្រោះបន្ទាន់ ក៏ត្រូវពិនិត្យមើលផងដែរ ។ នាយកដ្ឋានត្រួតពិនិត្យ ត្រូវអញ្ជើញប្រតិបត្តិករដោះមីន

មកបង្ហាញយ៉ាងហោចណាស់រៀងរាល់៣ខែម្តង អំពីការព្យាបាល និងបទដ្ឋានជម្លៀសជនរងគ្រោះ។ ស្តង់ដាស្តីពីការណែនាំដល់ប្រតិបត្តិករដោះមីន អំពីតម្រូវការអប្បបរមាសម្រាប់ការគាំទ្រផ្នែកពេទ្យ នឹងត្រូវបានចងក្រងនៅពេលខាងមុខ។

**៣.២.៥. ការរក្សាទុក ការដឹកជញ្ជូន និងការប្រើប្រាស់គ្រឿងផ្ទុះ**

លក្ខខ័ណ្ឌតម្រូវសម្រាប់សុវត្ថិភាពការងារ រួមមានៈ ការរក្សាទុក ការដឹកជញ្ជូន ការប្រើប្រាស់វំសេវផ្ទុះ និងសម្ភារៈគ្រឿងផ្ទុះ ដោយសុវត្ថិភាព។ ចំណុចនេះ តម្រូវឲ្យមានមធ្យោបាយទុកដាក់ សម្ភារៈឲ្យបានសមរម្យ រថយន្តសម្រាប់កិច្ចប្រតិបត្តិការដោះមីន និងនីតិវិធីក្នុងការថែទាំ។ អាជ្ញាធរមីន នឹងធ្វើការវាយតម្លៃលើបទដ្ឋាននានារបស់ប្រតិបត្តិករដោះមីន លើការរក្សាទុក ការដឹកជញ្ជូន និងការប្រើប្រាស់គ្រឿងផ្ទុះដោយសុវត្ថិភាព ព្រមទាំងការវាយតម្លៃពីរបៀបអនុវត្តបទដ្ឋាន ប្រកបដោយប្រសិទ្ធភាពខ្ពស់ ដូចបានប្រកាសនៅពេលសុំប័ណ្ណទទួលស្គាល់ ឬ អាជ្ញាប័ណ្ណ ។ អាជ្ញាធរមីន ត្រូវបញ្ជាក់ផងដែរពីឯកសារ បទដ្ឋាននានា សម្រាប់ការទទួលខុសត្រូវ និងដឹកជញ្ជូនគ្រឿងផ្ទុះ និងគ្រឿងបន្ទាប់បន្សំផ្សេងទៀត។ ការណែនាំពីការរក្សាទុក ការដឹកជញ្ជូន និងការប្រើប្រាស់វំសេវផ្ទុះដោយសុវត្ថិភាព មានចែងក្នុងស្តង់ដាជាតិ ជំពូក ៤ ។

**៣.២.៦. ការស៊ើបអង្កេតឧប្បត្តិហេតុ និងគ្រោះថ្នាក់**

អាជ្ញាធរមីន ត្រូវវាយតម្លៃលើភាពសមស្របនៃបទដ្ឋានសម្រាប់ធ្វើរបាយការណ៍ឧប្បត្តិហេតុ និងការស៊ើបអង្កេតក្រោយឧប្បត្តិហេតុរបស់អង្គការដោះមីន ។ ការណែនាំពីតម្រូវការអប្បបរមា សម្រាប់ធ្វើរបាយការណ៍ឧប្បត្តិហេតុ និងការស៊ើបអង្កេតក្រោយឧប្បត្តិហេតុ មានចែងក្នុងស្តង់ដាជំពូក ៥ ។

**៣.២.៧. ឧបករណ៍**

អាជ្ញាធរមីន ត្រូវវាយតម្លៃលើប្រសិទ្ធភាព និងភាពសមស្របនៃឧបករណ៍ ដែលរួមមាន ការធ្វើអធិការកិច្ចលើសំណៅជាគំរូនៃឧបករណ៍សំខាន់ៗ (ដូចជាម៉ាស៊ីនរាវមីន/UXO) និងពិនិត្យមើល កំណត់ត្រាក្នុងការថែទាំ ការជួសជុល និងការកែលំអឧបករណ៍ ។

**៣.២.៨. សកម្មភាពបោសសម្អាតមីន**

អាជ្ញាធរមីន ត្រូវសង្កេតមើលសកម្មភាពបោសសម្អាតមីន ដើម្បីធានាឲ្យសមស្របទៅតាម SOP របស់ប្រតិបត្តិករដោះមីន ។ អាជ្ញាធរមីន ត្រូវមានបុគ្គលិក ដែលមានចំណេះដឹងជំនាញឯកទេស នៅកន្លែងដែលមានការប្រើប្រាស់វិធីបោសសម្អាតមីនដោយជំនាញឯកទេស ដូចជា ការប្រើប្រាស់ឆ្កែហិតរកមីន ឬ ប្រព័ន្ធគ្រឿងយន្ត។ គោលការណ៍ណែនាំបន្ថែម លើការត្រួតពិនិត្យគម្រោងកម្មវិធី ដែលមានប្រើឆ្កែហិតរកមីន និងគ្រឿងយន្តជាជំនួយនឹងរៀបចំចងក្រងនៅពេលខាងមុខ។

**៣.៣.ការធ្វើរបាយការណ៍**

តំណាងអាជ្ញាធរមីន ត្រូវជូនដំណឹងទៅប្រធាន ឬ ផ្នែករងណាមួយរបស់ប្រតិបត្តិករដោះមីននោះ ពីកម្មវិធីត្រួតពិនិត្យជាមុន ដែលបង្ហាញពីចំនុចសំខាន់ៗ ទាក់ទងពិសេសទៅនឹងសុវត្ថិភាព បើអាចធ្វើបាន។

ភ្នាក់ងារត្រួតពិនិត្យ ត្រូវរៀបចំ និងដាក់ជូនអាជ្ញាធរមីននូវរបាយការណ៍ជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល១៥ថ្ងៃនៃថ្ងៃធ្វើការ អំពីការចុះធ្វើបេសកកម្មត្រួតពិនិត្យនេះ ដោយអនុលោមទៅតាមបទដ្ឋានរបស់អាជ្ញាធរ មីន ។ របាយការណ៍ នឹងត្រូវថតចម្លងឲ្យប្រតិបត្តិករដោះមីន ដែលត្រូវបានចុះត្រួតពិនិត្យ ។ តាមធម្មតា របាយការណ៍នេះ ត្រូវរក្សាការសម្ងាត់នៅដំណាក់កាលនេះ ពិសេសបើមានការរិះគន់ការគ្រប់គ្រង និងសកម្មភាពប្រតិបត្តិការរបស់ប្រតិបត្តិករដោះមីន ។

### ៣.៤.សកម្មភាពកែតម្រូវ

បញ្ហាទាំងឡាយណាដែលរកឃើញដោយនាយកដ្ឋានត្រួតពិនិត្យ ត្រូវមានការបកស្រាយបញ្ជាក់ ដោយប្រតិបត្តិករដោះមីន ។ ប្រសិនបើបញ្ហានោះមានភាពធ្ងន់ធ្ងរ អាជ្ញាធរមីនត្រូវធ្វើការកោះអញ្ជើញ ប្រតិបត្តិករដោះមីននោះ មកបង្ហាញពីសកម្មភាពកែតម្រូវការគ្រប់គ្រង ឬ បទដ្ឋានប្រតិបត្តិការរបស់ខ្លួន ឲ្យសមស្រប និងពេញលេញទៅតាមតម្រូវការដែលបានកំណត់ ។

## ៤.អង្គភាពត្រួតពិនិត្យ និង ភាពព្វកិច្ចទូទៅ

### ៤.១.ទូទៅ

អាជ្ញាធរមីន ត្រូវបង្កើតអង្គភាពត្រួតពិនិត្យមួយរបស់ខ្លួន។ អង្គភាពនេះ ត្រូវមានបុគ្គលិកគ្រប់គ្រាន់ បំពាក់ដោយសម្ភារៈ និងមានការបណ្តុះបណ្តាលត្រឹមត្រូវ ដើម្បីត្រួតពិនិត្យកិច្ចប្រតិបត្តិការរបស់ប្រតិបត្តិករដោះមីន និងអង្គភាពចំណុះរបស់គេ ឲ្យមានប្រសិទ្ធភាព និងសមស្រប ។

ភាពត្រួតពិនិត្យនេះ ត្រូវមានឯកសារគ្រប់គ្រាន់ដែលពណ៌នាពីការទទួលខុសត្រូវ និងវិធីប្រតិបត្តិការនៅក្នុងដំណើរការត្រួតពិនិត្យ និងទិដ្ឋភាពនៃសកម្មភាពបច្ចេកទេសរបស់ខ្លួន។ ក្នុងក្របខ័ណ្ឌ អាជ្ញាធរមីន មុខងារខាងអង្គភាព ផ្តល់ប័ណ្ណទទួលស្គាល់/អាជ្ញាប័ណ្ណ និងផ្នែកអធិការកិច្ច ត្រូវកំណត់ឲ្យបានច្បាស់លាស់ ។

### ៤.២.អង្គការចាត់តាំង

អង្គភាពត្រួតពិនិត្យ ត្រូវមានអង្គការចាត់តាំងមួយ ដែលមានលទ្ធភាពអនុវត្តមុខងារបច្ចេកទេស ឲ្យបានឆាប់រហ័ស និងពេញចិត្ត ។ អង្គភាពនេះ ត្រូវមានអ្នកគ្រប់គ្រងបច្ចេកទេសម្នាក់ ដែលមានគុណសម្បត្តិ និងបទពិសោធន៍នៅក្នុងកិច្ចប្រតិបត្តិការត្រួតពិនិត្យ និងមានការទទួលខុសត្រូវរួម សម្រាប់ធានាឲ្យសកម្មភាពត្រួតពិនិត្យប្រព្រឹត្តទៅដោយអនុលោមតាមស្តង់ដាសកម្មភាពមីនកម្ពុជា និងគោលការណ៍ណែនាំ បច្ចេកទេសផ្សេងទៀតដែលពាក់ព័ន្ធ។ អ្នកគ្រប់គ្រងបច្ចេកទេស គួរតែជានិយោជិកអចិន្ត្រៃយ៍ ប៉ុន្តែក៏អាច ជាទីប្រឹក្សាដែលមានគុណសម្បត្តិសមស្រប ។

អង្គភាពត្រួតពិនិត្យ ត្រូវមានចំនួនបុគ្គលិកអចិន្ត្រៃយ៍គ្រប់គ្រាន់ ដែលមានជំនាញតាមតម្រូវការ ដើម្បីអនុវត្តមុខងាររបស់ខ្លួន ។

### ៤.៣.ប្រព័ន្ធគ្រប់គ្រង

អង្គភាពត្រួតពិនិត្យ ត្រូវកំណត់ និងរៀបចំឯកសារប្រព័ន្ធគ្រប់គ្រង និងបទដ្ឋាននានារបស់ខ្លួន ហើយធានាថា គោលការណ៍គ្រប់គ្រងរបស់ខ្លួន ត្រូវបានអនុវត្ត និងប្រកាន់យកនៅគ្រប់លំដាប់ថ្នាក់ នៅក្នុងអង្គការចាត់តាំងរបស់ខ្លួន។ អាជ្ញាធរមីន និងប្រតិបត្តិករដោះមីន ត្រូវឯកភាពគ្នារៀបចំកិច្ចសន្យាតាមផ្នែក ប្រសិនបើប្រព័ន្ធគ្រប់គ្រង និងបទដ្ឋានត្រួតពិនិត្យនេះ ប៉ះពាល់ដល់ដំណើរការកម្មវិធីសកម្មភាពមីន។

អង្គភាពត្រួតពិនិត្យ ត្រូវរៀបចំ និងប្រកាន់យកការចុះពិនិត្យមើលការដ្ឋាន ។ អង្គភាពត្រួតពិនិត្យ ត្រូវរៀបចំ និងទុកដាក់កំណត់ហេតុចុះពិនិត្យមើលការដ្ឋានទាំងអស់ និងត្រូវធ្វើការពន្យល់ និងបកស្រាយឲ្យបានច្បាស់លាស់នូវកំណត់ហេតុដែលចាំបាច់។ កំណត់ហេតុទាំងអស់ ត្រូវទុកដាក់ឲ្យមានសុវត្ថិភាព សម្រាប់រយៈពេលយ៉ាងតិច៥ឆ្នាំ ដោយមានសន្តិសុខ និងរក្សាការសម្ងាត់ចំពោះអ្នកអនុវត្ត វៀរលែងតែមាន តម្រូវការដោយច្បាប់ ។

### ៤.៤.ឯករាជភាព អព្យាក្រឹតភាព និង បូរណភាព

បុគ្គលិករបស់អង្គភាពត្រួតពិនិត្យ មិនត្រូវជាប់ពាក់ព័ន្ធជាមួយក្រុមហ៊ុនពាណិជ្ជកម្ម ហិរញ្ញវត្ថុ ឬ ការគាបសង្កត់ផ្សេងៗ ដែលអាចជះឥទ្ធិពលលើការវិនិច្ឆ័យរបស់ខ្លួន។ គោលការណ៍ច្បាប់ និងបទដ្ឋាននានា នឹងត្រូវយក

មកអនុវត្ត ដើម្បីធានាថា បុគ្គល ឬស្ថាប័នក្រៅពីអង្គភាពត្រួតពិនិត្យ មិនអាចមានអានុភាពលើ លទ្ធផលនៃការស៊ើបអង្កេត ការធ្វើអធិការកិច្ច និងការវាយតម្លៃដែលអនុវត្តដោយអង្គភាពត្រួតពិនិត្យ។

អង្គភាពត្រួតពិនិត្យ និងបុគ្គលិករបស់ខ្លួន មិនត្រូវជាប់ពាក់ព័ន្ធក្នុងសកម្មភាពណាមួយ ដែលនាំទៅដល់ការខ្វែងគំនិតលើឯករាជភាពនៃការវិនិច្ឆ័យ និងបូរណភាពទំនាក់ទំនងការស៊ើបអង្កេត អធិការកិច្ច និងការវាយតម្លៃរបស់ខ្លួន ពិសេសពួកគេមិនត្រូវពាក់ព័ន្ធដោយផ្ទាល់ជាមួយក្រុមហ៊ុន/អង្គការដែលរចនាម៉ូដ ផលិត ផ្គត់ផ្គង់ បំពាក់ ប្រើប្រាស់ សេវាថែទាំ ឬផលិតសម្ភារៈសម្រាប់ប្រតិបត្តិករដោះមីន ដែលធ្វើប្រតិបត្តិការនៅក្នុងសកម្មភាពកំចាត់មីន ឬវិស័យដែលប្រហាក់ប្រហែលគ្នានោះទេ។

ភាគីពាក់ព័ន្ធទាំងអស់ ត្រូវមានលទ្ធភាពក្នុងការទទួលយកសេវាកម្មពីអង្គភាពត្រួតពិនិត្យ ។ បទដ្ឋាន ដែលប្រើប្រាស់ដោយអង្គភាពត្រួតពិនិត្យនេះ មិនត្រូវមានការរើសអើងឡើយ ។

អង្គភាពត្រួតពិនិត្យ ត្រូវធានាការសម្ងាត់នៃព័ត៌មាន ដែលបានទទួលនៅក្នុងសកម្មភាពត្រួតពិនិត្យរបស់ខ្លួន ។ សិទ្ធិជាម្ចាស់កម្មសិទ្ធិត្រូវបានការពារ ។

## ៥.ការទទួលខុសត្រូវ

### ៥.១.ការទទួលខុសត្រូវរបស់អាជ្ញាធរមីន

អាជ្ញាធរមីនត្រូវ ៖

ក)-បង្កើតប្រព័ន្ធត្រួតពិនិត្យ ប្រតិបត្តិករដោះមីន ដោយបំពេញទៅតាមនីតិវិធីនានា សម្រាប់ផ្តល់ប័ណ្ណទទួលស្គាល់ និងអធិការកិច្ចលើដីក្រោយពេលបោសសម្អាតមីន និងគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ។

ខ)-បង្កើតស្តង់ដាជាតិ និងផ្តល់គោលការណ៍ណែនាំបច្ចេកទេស សម្រាប់ត្រួតពិនិត្យ ប្រតិបត្តិករដោះមីន។

គ)-បង្កើត និងបណ្តុះបណ្តាលអង្គភាពត្រួតពិនិត្យ។

ឃ)-ឃ្លាំមើលការងាររបស់អង្គភាពត្រួតពិនិត្យ ដើម្បីធានាថា ប្រព័ន្ធត្រួតពិនិត្យដែលកំពុងអនុវត្តមានយុត្តិធម៌ និងសមធម៌ ដោយមិនរំខាន ឬ បង្អាក់ដល់គម្រោងការដោះមីន។

ង)-ធានានូវការដោះស្រាយដំណើរការប្តឹងតវ៉ា ដែលបានដាក់ជូនដោយប្រតិបត្តិករដោះមីន ដូចមាន រៀបរាប់នៅក្នុងស្តង់ដាជាតិ ជំពូក ២ ការផ្តល់ប័ណ្ណទទួលស្គាល់។ ធានាថា សកម្មភាពតាមដាន ដ៏សមស្របមួយ ត្រូវបានអនុវត្ត ទៅតាមអនុសាសន៍លើកឡើងដោយអង្គភាពត្រួតពិនិត្យ ។

### ៥.២.ការទទួលខុសត្រូវរបស់អង្គភាពត្រួតពិនិត្យ

អង្គភាពត្រួតពិនិត្យរបស់អាជ្ញាធរមីនត្រូវ ៖

ក)-អនុវត្តដំណើរការបណ្តុះបណ្តាលដែលចាំបាច់ និងការអភិវឌ្ឍ ដើម្បីជំរុញឲ្យមានសមត្ថភាពប្រតិបត្តិការសមជានាយកដ្ឋានត្រួតពិនិត្យ។

ខ)-រៀបចំគម្រោង និងកម្មវិធីត្រួតពិនិត្យ ដែលអនុញ្ញាតឲ្យនាយកដ្ឋានត្រួតពិនិត្យមានលទ្ធភាពក្នុងការចុះពិនិត្យប្រតិបត្តិករដោះមីន និងអង្គភាពចំណុះយ៉ាងមានប្រសិទ្ធភាព សុក្រឹតភាព និងពុំមានការវៀរះវៀរ។

គ)-រៀបចំផ្តល់ជូនឯកសារដល់ភាគីពាក់ព័ន្ធស្របច្បាប់ទាំងអស់ ដែលត្រូវចុះពិនិត្យ និងធ្វើអធិការកិច្ច ។

**៥.៣.ការទទួលខុសត្រូវរបស់ប្រតិបត្តិករដោះមីន**

ប្រតិបត្តិករដោះមីនត្រូវ ៖

ក)-អនុវត្តរបៀបគ្រប់គ្រង និងបទដ្ឋានប្រតិបត្តិការ លើកិច្ចការបោសសម្អាតមីន ទៅតាមតម្រូវការ ដែលមានចែងនៅក្នុងកិច្ចសន្យា ឬ កិច្ចព្រមព្រៀងជាផ្លូវការផ្សេង ដោយអនុលោមទៅតាមស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា (CMAS) ។

ខ)-ធានាឲ្យការធ្វើផែនការបោសសម្អាតមីន ឲ្យមានការពិគ្រោះយោបល់ជាមួយអាជ្ញាធរមីន ស្របទៅតាមស្តង់ដា និងអាទិភាពរបស់ជាតិ ។

គ)-ថែរក្សា និងរៀបចំឲ្យមានឯកសារ របាយការណ៍ កំណត់ហេតុ និង ទិន្នន័យផ្សេងទៀត ស្តីពីសកម្មភាពដោះមីនសម្រាប់នាយកដ្ឋានត្រួតពិនិត្យ ។

ឃ)-ផ្តល់ឲ្យអាជ្ញាធរមីន ចេញចូលគ្រប់ការដ្ឋាន អគារ និង មធ្យោបាយផ្សេងទៀត ដែលជាតម្រូវការសម្រាប់ផ្នែកត្រួតពិនិត្យ។

**៥.៤.ការទទួលខុសត្រូវរបស់ប្រទេសផ្តល់ជំនួយ**

រាល់កិច្ចសន្យា ឬ កិច្ចព្រមព្រៀងជាផ្លូវការដទៃទៀត ដែលធ្វើគម្រោងដោយប្រទេសផ្តល់ជំនួយ ត្រូវដាក់បញ្ចូលការទទួលខុសត្រូវ នូវព័ត៌មានលំអិតស្តីពី តម្រូវការត្រួតពិនិត្យរបស់ជាតិ។ ប្រទេសផ្តល់ជំនួយ ក៏ទទួលខុសត្រូវផងដែរ ដើម្បីធានាថាសកម្មភាពដោះមីន ត្រូវបានរៀបចំដោយមានការសម្របសម្រួលជាមួយ អាជ្ញាធរមីន ស្របទៅតាមគោលការណ៍ច្បាប់ និងអាទិភាពរបស់ជាតិដែលបានកំណត់ ។

***